**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌
លេខ ០៨ សប-៩៧

# សារាចរ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបចក**

លោកប្រធានតុលាការគ្រប់ខេត្ត ក្រុង

ព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** ការកាន់កាប់ប្រើប្រាស់ការលាក់ទុក និងការដឹកជញ្ជូនអាវុធគ្រឿងផ្ទុះខុសច្បាប់ ។

ខ្ញុំសូមជម្រាបលោកថា ចាប់តាំងពីថ្ងៃនេះតទៅជនណាដែលកាន់កាប់ ប្រើប្រាស់ លាក់ទុក និងដឹកជញ្ជូនអាវុធយុទ្ធភណ្ឌ និងគ្រឿងផ្ទុះផ្សេងៗ ខុសច្បាប់ជននោះត្រូវជាប់ចោទ និងផ្តន្ទាទោសតាមមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូចធម្មតា ។

ម៉្យាងទៀតបទល្មើសនេះ ជាបទល្មើសជាក់ស្តែងអយ្យការត្រូវសហការណែនាំមន្ត្រីនគរបាលយុត្តិធម៌ឱ្យចាត់វិធានការរឿងបែបនេះភ្លាមៗ ជូនមកអយ្យការបន្ទាប់មកអយ្យការត្រូវធ្វើការចោទប្រកាន់ដាក់ជូនទៅតុលាការជំនុំជម្រះភ្លាម តាមរបៀបចាត់ការបទល្មើសជាក់ស្តែង ដោយមិនបាច់ជូនទៅចៅក្រមស៊ើបអង្កេតដើម្បីស៊ើបសួរនាំអោយខាតពេលយូរនោះទេ ។

ក្រសួងយុត្តិធម៌ សង្ឃឹមថាអស់លោកនឹងចាត់ការតាមការណែនាំនៃសារាចរនេះអោយបានម៉ឺងម៉ាត់ និងហ្មត់ចត់ជាទីបំផុត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន

-ប្រធានតុលាការកំពូល

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-ប្រធានសាលាឧទ្ធរណ៍

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍